**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្តីសម្រេចចិត្ត
## មហាសន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ ទូទាំងប្រទេសឆ្នាំ២០២៣ និងកំណត់ទិសដៅការងារជាអាទិភាពបន្ត

មហាសន្និបាតបូកសរុបលទ្ធផលការងារវិស័យយុត្តិធម៌ទូទាំងប្រទេសឆ្នាំ២០២៣ និងកំណត់ទិសដៅការងារជាអាទិភាពបន្ត បានប្រព្រឹត្តទៅរយៈពេល ៣ថ្ងៃពេញ ចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌, ឯកឧត្តម បណ្ឌិត ជីវ កេង** ប្រធានតុលាការកំពូល និង **លោកជំទាវ ជា លាង** អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល។ មហាសន្និបាតនេះ មានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ ជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម, ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំនៃក្រសួងយុត្តិធម៌ ព្រមទាំង ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ ជាចៅក្រម និងព្រះរាជអាជ្ញា នៃសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់នៅទូទាំងប្រទេស និង ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំនៃអង្គភាពរដ្ឋបាលតុលាការនៅទូទាំងប្រទេស សរុបចំនួនប្រមាណជាង **៧៥០ រូប**។

មហាសន្និបាតវិស័យយុត្តិធម៌នេះ មិនត្រឹមតែជាការជួបជុំដ៏ធំលើកទី១ ពុំធ្លាប់មានក្នុងវិស័យយុត្តិធម៌ និងត្រូវបានចាត់ទុកថាជា **"ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រថ្មីមួយទៀតសម្រាប់វិស័យយុត្តិធម៌"** ប៉ុណ្ណោះទេ ប៉ុន្តែព្រឹត្តិការណ៍នេះត្រូវបានរៀបចំឡើងក្នុងបរិការណ៍នៃការចាប់ផ្តើមចេញដំណើររបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានកំណត់យក **"ការពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពនៃច្បាប់ និងប្រព័ន្ធយុត្តិធម៌"** ជាមុំមួយក្នុងចំណោមមុំទាំង ៥ ដែលបង្កើតបានជាស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល និងជាវិធានការគន្លឹះមួយក្នុងចំណោមវិធានការគន្លឹះទាំង៥ របស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី**។ មហាសន្និបាតនេះ ក៏ត្រូវបានរៀបចំឡើងស្របពេលដែលវិស័យយុត្តិធម៌ទាំងមូល បាននិងកំពុងខិតខំប្រឹងប្រែងរួមគ្នាក្នុងការអនុវត្ត **"យុទ្ធនាការជំរុញនិងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ"** និង **"យុទ្ធនាការត្រួតពិនិត្យនិងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ"** ផងដែរ។ មហាសន្និបាតវិស័យយុត្តិធម៌លើកទី១ ត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បីអនុញ្ញាតឱ្យចៅក្រម ព្រះរាជអាជ្ញា និងតួអង្គដែលមានការពាក់ព័ន្ធក្នុងវិស័យយុត្តិធម៌ទាំងអស់ ពិនិត្យ និងពិភាក្សាលើបញ្ហាប្រឈមសំខាន់ៗមួយចំនួនដែលធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងប្រសិទ្ធភាពនៃការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ព្រមទាំងសម្រេចដាក់ចេញនូវដំណោះស្រាយរួមចំពោះបញ្ហាប្រឈមទាំងនោះ ដែលអាចធានាបាននូវការឯកភាពទាំងលើគោលជំហរ ទាំងលើទស្សនៈ ដើម្បីធានាប្រសិទ្ធភាព និងសង្គតិភាព សម្រាប់ការអនុវត្តនៅតាមសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ សំដៅ **"រួមគិត រួមធ្វើ រួមទទួលខុសត្រូវ"** ក្នុងចក្ខុវិស័យរួមតែមួយក្នុងជំហានកាន់តែបុរេសកម្ម កាន់តែសកម្ម កាន់តែស្វាហាប់ និងប្រកបដោយការទទួលខុសត្រូវខ្ពស់ ដើម្បីនាំមកនូវការប្រែប្រួលជាវិជ្ជមាននូវមុខមាត់នៃវិស័យយុត្តិធម៌នៅក្នុងសង្គមជាតិ។



KR

អង្គមហាសន្និបាតបានពិនិត្យ និងពិភាក្សាលើប្រធានបទសរុបចំនួន ៨ ពាក់ព័ន្ធនឹងបញ្ហាប្រឈមសំខាន់ៗមួយចំនួនដែលប៉ះពាល់ដល់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងប្រសិទ្ធភាពនៃការផ្តល់សេវាយុត្តិធម៌នាពេលកន្លងមក ដែលក្នុងនោះ**ប្រធានបទចំនួន ៤ ពាក់ព័ន្ធនឹងវិស័យរដ្ឋប្បវេណី** ដែលរួមមាន៖ (**ទី១**)-ការអនុវត្តក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី៖ ប្រសិទ្ធភាព និងបញ្ហាប្រឈម, (**ទី២**)-ការចេញដីកាសម្រេចរក្សាការពារ, (**ទី៣**)-ការលើកកម្ពស់ប្រសិទ្ធភាព និងជំនឿទុកចិត្តលើការលក់ដោយបង្ខំនូវអចលនវត្ថុ និង (**ទី៤**)-ការជូនដំណឹង និងការបញ្ជូនសេចក្តីសម្រេចរបស់តុលាការ និង**ប្រធានបទចំនួន ៤ ទៀតពាក់ព័ន្ធនឹងវិស័យព្រហ្មទណ្ឌ** ដែលរួមមាន៖ (**ទី១**)-ការអនុវត្តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ៖ ប្រសិទ្ធភាព និងបញ្ហាប្រឈម, (**ទី២**)-ការជូនដំណឹងអំពីសាលក្រមកំបាំងមុខ (ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ), (**ទី៣**)-បទល្មើសប្រព្រឹត្តដោយអនីតិជន និង (**ទី៤**)-បណ្តឹងឧទ្ធរណ៍ និងបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះសាលក្រម ឬសាលដីកាក្នុងរឿងព្រហ្មទណ្ឌ។

ឆ្លងតាមការពិភាក្សា និងផ្លាស់ប្តូរយោបល់យ៉ាងផុលផុសលើប្រធានបទនីមួយៗរួចមក, អង្គមហាសន្និបាត បានឯកភាពលើខ្លឹមសារនៃសេចក្តីសម្រេចចិត្តរួម ដូចខាងក្រោម៖

**ប្រធានបទទី១-ការអនុវត្តក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី៖ ប្រសិទ្ធភាព និងបញ្ហាប្រឈម**

អង្គមហាសន្និបាតវិស័យយុត្តិធម៌ សម្តែងនូវអំណរគុណ និងការដឹងគុណយ៉ាងជ្រាលជ្រៅជូនចំពោះរាជរដ្ឋាភិបាល និងប្រជាជនជប៉ុន, ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA), សាស្ត្រាចារ្យ និងអ្នកជំនាញការជប៉ុនទាំងអស់ ដែលបានផ្តល់ការគាំទ្រ និងជំនួយនានា ប្រកបដោយការទទួលខុសត្រូវដល់វិស័យយុត្តិធម៌របស់ព្រះរាជាណាចក្រកម្ពុជា តាមរយៈ "**គម្រោងអភិវឌ្ឍន៍វិស័យច្បាប់និងយុត្តិធម៌**" រយៈពេលជាង ២០ឆ្នាំ កន្លងមកនេះ ដោយបានកសាងនូវប្រព័ន្ធច្បាប់រដ្ឋប្បវេណីមួយយ៉ាងពេញលេញសម្រាប់ព្រះរាជាណាចក្រកម្ពុជា ព្រមទាំងបានបណ្តុះបណ្តាលកសាងសមត្ថភាពមន្ត្រីអនុវត្តច្បាប់កម្ពុជា ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យរដ្ឋប្បវេណីនេះ។

ឆ្លងកាត់ការអនុវត្តក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីអស់រយៈពេលជិត ២០ឆ្នាំ កន្លងទៅនេះ, អង្គមហាសន្និបាត បានពិនិត្យឃើញកញ្ចប់បញ្ហាចំនួន ៤ រួមមាន៖ (១)-ការប្រើពាក្យពេចន៍ និងឃ្លាឃ្លោងដែលពិបាកយល់, (២)-សង្គតិភាពរវាងបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីជាមួយច្បាប់ផ្សេងទៀត, (៣)-កង្វះនូវបទប្បញ្ញត្តិមួយចំនួន និង (៤)-ការមិនអាចអនុវត្តបាននូវបទប្បញ្ញត្តិមួយចំនួនក្នុងការជាក់ស្តែង។

ចំពោះកញ្ចប់បញ្ហាទាំងនេះ, អង្គមហាសន្និបាត បានសម្រេចឯកភាពគ្នាលើភាពចាំបាច់ក្នុងការពិនិត្យ និងសិក្សាដើម្បីធ្វើវិសោធនកម្មក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ព្រមទាំងច្បាប់ពាក់ព័ន្ធក្នុងវិស័យរដ្ឋប្បវេណី សំដៅធ្វើឱ្យប្រសើរឡើងនូវបទប្បញ្ញត្តិដែលមានចែងនៅក្នុងក្រមទាំងពីរនេះ ដើម្បីដោះស្រាយនូវបញ្ហាប្រឈមនានាក្នុងការអនុវត្តដែលមាននាពេលកន្លងមក និងអាចឆ្លើយតបទៅនឹងតថភាពជាក់ស្តែងនៃសង្គមកម្ពុជា ជាពិសេស ក្នុងបរិការណ៍នៃឌីជីថលូបនីយកម្ម។ ទន្ទឹមនេះ, អង្គមហាសន្និបាត បានសម្រេចប្រគល់ភារកិច្ចជូនក្រុមការងារបច្ចេកទេសរៀបចំការធ្វើវិសោធនកម្មច្បាប់ក្នុងវិស័យរដ្ឋប្បវេណី ដែលបង្កើតឡើងដោយក្រសួងយុត្តិធម៌ ដើម្បីយកចំណុចសំខាន់ៗដែលបានពិភាក្សាក្នុងមហាសន្និបាតនេះ ជាធាតុចូលសម្រាប់ការរៀបចំសេចក្តីព្រាងវិសោធនកម្មច្បាប់ក្នុងវិស័យនេះ ដោយមិនត្រូវធ្វើឱ្យប៉ះពាល់នូវគោលការណ៍គ្រឹះសំខាន់ៗ និងរចនាសម្ព័ន្ធនៃក្រមទាំងពីរនេះ ព្រមទាំងធ្វើការពិគ្រោះយោបល់ជាមួយអ្នកជំនាញការជប៉ុនក្នុងក្របខ័ណ្ឌនៃគម្រោងអភិវឌ្ឍន៍វិស័យច្បាប់ និងយុត្តិធម៌។

KR

## ប្រធានបទទី២-ការចេញដីកាសម្រេចរក្សាការពារ

ពាក់ព័ន្ធនឹងប្រធានបទនេះ, អង្គមហាសន្និបាត បានពិនិត្យឃើញកញ្ចប់បញ្ហាចំនួន ៣ រួមមាន៖ (១)-ការចេញដីកាសម្រេចរក្សាការពារមិនត្រឹមត្រូវតាមប្រភេទនៃការចាត់ចែងរក្សាការពារ និងមិនទាន់មានសង្គតិភាពលើទម្រង់នៃដីកាសម្រេចរក្សាការពារ ព្រមទាំងពុំមានលក្ខខណ្ឌតាមច្បាប់គ្រប់គ្រាន់ក្នុងការចេញដីកាសម្រេចរក្សាការពារ, (២)-ការចាត់ចែងរក្សាការពារចំពោះអចលនវត្ថុដែលមិនបានចុះបញ្ជីសុរិយោដីនៅមិនទាន់អាចធ្វើបាន និង (៣)-ការមិនអាចអនុវត្តបាននូវដីកាសម្រេចរក្សាការពារមួយចំនួន។

ចំពោះកញ្ចប់បញ្ហាទាំងនេះ, អង្គមហាសន្និបាតវិស័យយុត្តិធម៌ បានឯកភាពគ្នាសម្រេច ដូចខាងក្រោម៖

១-រៀបចំ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវទម្រង់រួមនៃដីកាសម្រេចរក្សាការពារ នៅតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ដើម្បីធានាសង្គតិភាព ទាំងលើទម្រង់នៃដីកា ទាំងលើខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់តាមប្រភេទនៃការចាត់ចែងរក្សាការពារ និងអាចយកទៅអនុវត្តបានប្រកបដោយប្រសិទ្ធភាព។ ក្នុងការអនុវត្តការងារនេះ, អង្គមហាសន្និបាត បានសម្រេចប្រគល់ភារកិច្ចជូន ក្រសួងយុត្តិធម៌ ដើម្បីរៀបចំឱ្យមានទម្រង់រួមនៃដីកាសម្រេចរក្សាការពារ ដោយមានការពិគ្រោះយោបល់ជាមួយសាលាជម្រះក្តីទាំងអស់មុននឹងដាក់ឱ្យអនុវត្តនៅទូទាំងប្រទេស។

២-យន្តការវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវពង្រឹងការត្រួតពិនិត្យខាងវិន័យ ក្នុងករណីចៅក្រមប្រើឆន្ទានុសិទ្ធិដោយរំលោភបំពានក្នុងការចេញដីកាសម្រេចរក្សាការពារ សំដៅធានាការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ និងលើកកម្ពស់ជំនឿទុកចិត្តរបស់សាធារណជនលើវិស័យយុត្តិធម៌។

## ប្រធានបទទី៣-ការលើកកម្ពស់ប្រសិទ្ធភាព និងជំនឿទុកចិត្តលើការលក់ដោយបង្ខំនូវអចលនវត្ថុ

ពាក់ព័ន្ធនឹងប្រធានបទនេះ, អង្គមហាសន្និបាត បានពិនិត្យឃើញកញ្ចប់បញ្ហាចំនួន ៣ រួមមាន៖ (១)-ការកំណត់តម្លៃលក់អប្បបរមានៃអចលនវត្ថុមិនមានភាពច្បាស់លាស់ ដោយមិនទាន់បានកំណត់ច្បាស់លាស់នូវស្ថាប័ន ឬយន្តការធ្វើការវាយតម្លៃអចលនវត្ថុដែលជាកម្មវត្ថុនៃការលក់ដោយបង្ខំ, (២)-ការផ្សព្វផ្សាយជាសាធារណៈអំពីការលក់ឡាយឡុង មិនបានទូលំទូលាយ និង (៣)-ការអូសបន្លាយពេលវេលានៃការអនុវត្តការលក់ដោយបង្ខំដោយតុលាការ ដោយសារភាពស្មុគស្មាញនៃនីតិវិធីជាធរមាន។

ចំពោះកញ្ចប់បញ្ហាទាំងនេះ, អង្គមហាសន្និបាតវិស័យយុត្តិធម៌ បានឯកភាពគ្នាសម្រេច ដូចខាងក្រោម៖

១-ការផ្សព្វផ្សាយជាសាធារណៈអំពីការលក់ដោយបង្ខំតាមផ្លូវតុលាការ ត្រូវធ្វើឡើងឱ្យបានទូលំទូលាយ។ ក្នុងការអនុវត្តការងារនេះ, ក្រសួងយុត្តិធម៌ នឹងបង្កើតឱ្យមានបណ្តាញទំនាក់ទំនងសង្គមផ្លូវការ ជាអាទិ៍ Facebook ឬ Telegram ដើម្បីផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការលក់ដោយបង្ខំតាមផ្លូវតុលាការ។ ទន្ទឹមនេះ, សាលាជម្រះក្តីនីមួយៗអាចបង្កើតព្រឹត្តិបត្រព័ត៌មាន ដើម្បីផ្សព្វផ្សាយនៅតាមបណ្តាញសង្គមផ្លូវការរបស់ខ្លួនផងដែរ។

២-ដើម្បីធានាតម្លាភាព និងជំនឿទុកចិត្តក្នុងការកំណត់តម្លៃនៃអចលនវត្ថុដែលត្រូវលក់ដោយបង្ខំតាមផ្លូវតុលាការ, ការវាយតម្លៃអចលនវត្ថុដែលត្រូវលក់ដោយបង្ខំ ត្រូវធ្វើឡើងដោយក្រុមហ៊ុនវាយតម្លៃអចលនទ្រព្យ ដែលទទួលស្គាល់ដោយក្រសួងយុត្តិធម៌។ ក្នុងការអនុវត្តការងារនេះ, ក្រសួងយុត្តិធម៌ នឹងពិចារណាចុះកិច្ចព្រមព្រៀង ឬអនុស្សរណៈនៃការយោគយល់គ្នា ជាមួយក្រុមហ៊ុនវាយតម្លៃអចលនទ្រព្យ។ ដើម្បីធានាប្រសិទ្ធភាព និងសង្គតិភាពនៃការអនុវត្ត, ក្រសួងយុត្តិធម៌ និងតុលាការកំពូល នឹងដាក់ចេញនូវសេចក្តីណែនាំរួម ពាក់ព័ន្ធនឹងការងារនេះ។

KR

៣-នីតិវិធីនៃការលក់ដោយបង្ខំចំពោះអចលនវត្ថុ នឹងត្រូវបានពិនិត្យកែសម្រួលឡើងវិញឱ្យមានលក្ខណៈសាមញ្ញ និងងាយស្រួលក្នុងការអនុវត្ត នៅក្នុងក្របខ័ណ្ឌនៃការធ្វើវិសោធនកម្មក្រមនីតិវិធីរដ្ឋប្បវេណី ដើម្បីធានាភាពឆាប់រហ័ស និងប្រសិទ្ធភាពនៃការអនុវត្តការលក់ដោយបង្ខំនេះ។

## ប្រធានបទទី៤-ការជូនដំណឹង និងការបញ្ជូនសេចក្ដីសម្រេចរបស់តុលាការ

ចំពោះប្រធានបទនេះ, អង្គមហាសន្និបាត បានពិនិត្យឃើញកញ្ចប់បញ្ហាចំនួន ៤ រួមមាន៖ (១)-បញ្ហាកង្វះមន្ត្រីប្រតិបត្តិកិច្ចការបញ្ជូន, (២)-ការអនុវត្តមិនបានត្រឹមត្រូវរបស់មន្ត្រីប្រតិបត្តិកិច្ចការបញ្ជូន, (៣)-វិធីបញ្ជូនដែលបានកំណត់ក្នុងច្បាប់លែងឆ្លើយតបនឹងស្ថានភាពវិវត្តរបស់សង្គម និងបច្ចេកវិទ្យាឌីជីថល និង (៤)-ការអនុវត្តមិនត្រឹមត្រូវនៃការបញ្ជូនតាមការផ្សាយជាសាធារណៈ។

ចំពោះកញ្ចប់បញ្ហាទាំងនេះ, អង្គមហាសន្និបាតវិស័យយុត្តិធម៌ បានឯកភាពគ្នាសម្រេច ដូចខាងក្រោម៖

១-ក្នុងអំឡុងពេលរង់ចាំច្បាប់ស្ដីពីអាជ្ញាសាលាត្រូវបានរៀបចំនិងអនុម័តឱ្យប្រើ, ក្រសួងយុត្តិធម៌ ត្រូវរៀបចំឱ្យមានមន្ត្រីទទួលបន្ទុកប្រតិបត្តិកិច្ចការបញ្ជូន ដែលនឹងទទួលបានប្រតិភូកម្មអំណាចពីអាជ្ញាសាលា ឬក្រឡាបញ្ជី ហើយដែលស្ថិតក្រោមការទទួលខុសត្រូវរួមរបស់ប្រធានសាលាជម្រះក្ដី ដើម្បីអនុវត្តកិច្ចការបញ្ជូន។

២-ក្រសួងយុត្តិធម៌ នឹងសហការជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីរៀបចំឱ្យមានយន្តការរួមមួយ សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃក្នុងការអនុវត្តកិច្ចការបញ្ជូនឱ្យបានឆាប់រហ័ស និងឱ្យបានត្រឹមត្រូវតាមការកំណត់របស់ច្បាប់ជាធរមាន។

៣-ក្នុងការធ្វើវិសោធនកម្មក្រមនីតិវិធីរដ្ឋប្បវេណី នឹងត្រូវបញ្ចូលបន្ថែមនូវរបៀបនៃការបញ្ជូន ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ឬប្រព័ន្ធទំនាក់ទំនងសង្គម ដែលអាចធានាបាននូវប្រសិទ្ធភាព, ភាពឆាប់រហ័ស និងកាត់បន្ថយការចំណាយថវិកាលើកិច្ចការបញ្ជូននេះ។

## ប្រធានបទទី៥-ការអនុវត្តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ៖ ប្រសិទ្ធភាព និងបញ្ហាប្រឈម

អង្គមហាសន្និបាតវិស័យយុត្តិធម៌ សម្ដែងនូវអំណរគុណដល់ជំនួយនៃសហប្រតិបត្តិការរបស់សាធារណរដ្ឋបារាំង និងប្រជាជនបារាំង ដែលបានផ្ដល់នូវកិច្ចសហប្រតិបត្តិការក្នុងការកសាងក្របខ័ណ្ឌច្បាប់ព្រហ្មទណ្ឌសម្រាប់ព្រះរាជាណាចក្រកម្ពុជា ដែលជាមូលដ្ឋានគតិយុត្ត និងគ្រឹះនៃច្បាប់ដ៏សំខាន់ សម្រាប់អ្នកអនុវត្តច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ដើម្បីបង្ការ បង្ក្រាប និងទប់ស្កាត់បទល្មើសប្រកបដោយប្រសិទ្ធភាព តម្លាភាព និងធានាបាននូវការការពារសិទ្ធិ សេរីភាព និងផលប្រយោជន៍របស់ប្រជាពលរដ្ឋ ព្រមទាំងចូលរួមចំណែកក្នុងការពង្រឹងសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងស្ថិរភាពសង្គម។

ឆ្លងកាត់ការអនុវត្តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ អស់រយៈពេលជាង ១៥ ឆ្នាំកន្លងទៅនេះ, អង្គមហាសន្និបាត បានពិនិត្យឃើញនូវកញ្ចប់បញ្ហាចំនួន ៤ រួមមាន៖ (**ទី១**)-បទប្បញ្ញត្តិមួយចំនួននៅមានភាពមិនទាន់ច្បាស់លាស់ ឬមិនទាន់រលូន ដែលធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៅក្នុងការអនុវត្ត, (**ទី២**)-បទប្បញ្ញត្តិមួយចំនួននៅមិនទាន់អាចឆ្លើយតបទៅនឹងស្ថានភាពនៃសង្គមជាក់ស្ដែង, (**ទី៣**)-ភាពចាំបាច់ក្នុងការរៀបចំបទប្បញ្ញត្តិថ្មីៗបន្ថែម ដើម្បីឆ្លើយតបទៅនឹងការវិវត្តនៃបច្ចេកវិទ្យាឌីជីថល និង (**ទី៤**)-ក្នុងករណីចាំបាច់ ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនឹងអាចត្រូវពិនិត្យមើលឡើងវិញ ដើម្បីធានាប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនៅកម្ពុជា។

KR

ចំពោះកញ្ចប់បញ្ហាទាំងនេះ, អង្គមហាសន្និបាត បានសម្រេចឯកភាពគ្នា លើភាពចាំបាច់ក្នុងការធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌ, ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ពាក់ព័ន្ធក្នុងវិស័យព្រហ្មទណ្ឌ ដើម្បីដោះស្រាយប្រកបដោយប្រសិទ្ធភាពនូវការលំបាកនៅក្នុងការអនុវត្ត, បំពេញបន្ថែមនូវចំណុចខ្វះខាត ដោយផ្អែកតាមការវិវត្តនៃស្ថានភាពសង្គម និងបច្ចេកវិទ្យា ព្រមទាំងដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនៅកម្ពុជា។

**<u>ប្រធានបទទី៦-ការជូនដំណឹងអំពីសាលក្រមកំបាំងមុខ (ការជូនដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការ)</u>**

ចំពោះប្រធានបទនេះ, អង្គមហាសន្និបាត បានពិនិត្យឃើញកញ្ចប់បញ្ហាចំនួន ២ រួមមាន៖ (**ទី១**)-បទប្បញ្ញត្តិច្បាប់មួយចំនួនមានភាពមិនច្បាស់លាស់ដែលនាំឱ្យមានការបកស្រាយផ្សេងគ្នា និងការអនុវត្តមិនមានសង្គតិភាព និង (**ទី២**)-បញ្ហាប្រឈមក្នុងការជូនដំណឹងដែលធ្វើឱ្យសេចក្ដីសម្រេចមួយចំនួនរបស់តុលាការមិនអាចចូលជាស្ថាពរបាន។

ចំពោះកញ្ចប់បញ្ហាទាំងនេះ, អង្គមហាសន្និបាត បានសម្រេចឯកភាពគ្នាថា ត្រូវបន្តអនុវត្តស្របតាមមាតិកាទី៤ ចាប់ពីមាត្រា៤៨២ ដល់មាត្រា៤៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ប៉ុន្តែ, ដើម្បីដោះស្រាយបញ្ហាចំពោះមុខ និងក្នុងអំឡុងពេលនៃការរង់ចាំការធ្វើវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ, អង្គមហាសន្និបាតបានសម្រេចឯកភាពគ្នាលើវិធានការបំពេញបន្ថែម ដូចខាងក្រោម៖

**១**-ការជូនដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការក្នុងសំណុំរឿងព្រហ្មទណ្ឌ អាចធ្វើឡើងតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ស្របតាមស្មារតីនៃមាត្រា៤៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**២**-បន្ថែមលើការអនុវត្តនីតិវិធីនៃការជូនដំណឹងដែលបានអនុវត្តនាពេលកន្លងមក ស្របតាមមាត្រា៤៨៨ និងមាត្រា៤៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ, ការជូនដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការក្នុងសំណុំរឿងព្រហ្មទណ្ឌ អាចធ្វើឡើងតាមរយៈសារព័ត៌មាន ឬតាមយន្តការផ្សព្វផ្សាយតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថលក្នុងវិស័យយុត្តិធម៌ ក្នុងករណីដែលភាគីពាក់ព័ន្ធអវត្តមានពីលំនៅឋាន ឬពុំមានលំនៅឋានឬទីសំណាក់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្រសួងយុត្តិធម៌ និងតុលាការកំពូលនឹងដាក់ចេញនូវសេចក្ដីណែនាំរួមអំពីការជូនដំណឹងនេះ ដើម្បីធានាបាននូវការឯកភាពក្នុងការអនុវត្ត។

**<u>ប្រធានបទទី៧-បទល្មើសប្រព្រឹត្តដោយអនីតិជន</u>**

ចំពោះប្រធានបទនេះ, អង្គមហាសន្និបាត បានពិនិត្យឃើញកញ្ចប់បញ្ហាចំនួន ៤ រួមមាន៖ (**ទី១**)-ការអនុវត្តនីតិវិធី និងវិធានពិសេស ដែលមានចែងនៅក្នុងច្បាប់ស្ដីពីយុត្តិធម៌អនីតិជននៅមានកម្រិត, (**ទី២**)-កង្វះទីកន្លែងសម្រាប់ទទួលថែរក្សាអនីតិជនទំនាស់នឹងច្បាប់ក្នុងករណីមានការអនុវត្តវិធានការបង្វែរ និង (**ទី៣**)-ការខ្វែងគំនិតគ្នាលើការលើកយកស្ថានសម្រាល ឬស្ថានទម្ងន់ទោសមកអនុវត្ត ជាពិសេស ការថ្លឹងថ្លែងរវាងផលប្រយោជន៍របស់ជនល្មើសជាអនីតិជន, ផលប្រយោជន៍របស់ជនរងគ្រោះ និងផលប្រយោជន៍នៃសន្តិសុខសង្គម និងសណ្ដាប់ធ្នាប់សាធារណៈ។

ចំពោះកញ្ចប់បញ្ហាទាំងនេះ, អង្គមហាសន្និបាត បានសម្រេចឯកភាពគ្នាក្នុងការបន្តពង្រឹងការអនុវត្តបទប្បញ្ញត្តិដែលមានស្រាប់ទាក់ទងនឹងអនីតិជនទំនាស់នឹងច្បាប់ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ, ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ស្ដីពីយុត្តិធម៌អនីតិជន។ ទន្ទឹមនេះ, អង្គមហាសន្និបាតគាំទ្រការកំណត់យក


KR

វិធានការបង្វែរជាវិធានការអាទិភាពដែលត្រូវអនុវត្តតាមការកំណត់របស់ច្បាប់នៅក្នុងសំណុំរឿងព្រហ្មទណ្ឌពាក់ព័ន្ធនឹងអនីតិជន ប៉ុន្តែ ត្រូវពិចារណាថ្លឹងថ្លែងឱ្យបានច្បាស់លាស់អំពីផលប្រយោជន៍របស់អនីតិជនទំនាស់នឹងច្បាប់ និងផលប្រយោជន៍នៃសន្តិសុខសង្គម និងសណ្តាប់ធ្នាប់សាធារណៈ ទៅតាមករណីជាក់ស្តែងនីមួយៗ។

**ប្រធានបទទី៨-បណ្តឹងឧទ្ធរណ៍ និងបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះសាលក្រម ឬសាលដីកាក្នុងរឿងព្រហ្មទណ្ឌ**

ពាក់ព័ន្ធនឹងប្រធានបទនេះ, អង្គមហាសន្និបាត បានពិនិត្យឃើញកញ្ចប់បញ្ហាចំនួន ៣ រួមមាន៖ (**ទី១**)-បទប្បញ្ញត្តិច្បាប់មួយចំនួនមានភាពមិនច្បាស់លាស់ដែលនាំឱ្យមានការបកស្រាយផ្សេងគ្នា និងការអនុវត្តមិនមានសង្គតិភាព, (**ទី២**)-អគ្គព្រះរាជអាជ្ញា និងព្រះរាជអាជ្ញាមិនបានប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួនក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងសាទុក្ខ ឬមិនបានការពារបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងសាទុក្ខរបស់ខ្លួន និង (**ទី៣**)-ការទទួលយក និងការសម្រេចអំពីបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងព្រហ្មទណ្ឌ នៅមិនទាន់មានសង្គតិភាពរវាងសាលាជម្រះក្តីនានា។

ចំពោះកញ្ចប់បញ្ហាទាំងនេះ, អង្គមហាសន្និបាត បានសម្រេចឯកភាពគ្នា ដូចខាងក្រោម៖

**១**-អគ្គព្រះរាជអាជ្ញា និងព្រះរាជអាជ្ញាទាំងអស់ ត្រូវពង្រឹងតួនាទី, ភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួនក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងសាទុក្ខ និងត្រូវការពារបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងសាទុក្ខរបស់ខ្លួនក្នុងសំណុំរឿងព្រហ្មទណ្ឌឱ្យបានត្រឹមត្រូវស្របតាមច្បាប់ ដើម្បីធានាការពារសន្តិសុខសង្គម និងផលប្រយោជន៍សាធារណៈ។

**២**-ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ មានសិទ្ធិក្នុងការធ្វើបណ្តឹងឧទ្ធរណ៍ និងបណ្តឹងសាទុក្ខ ស្របតាមមាត្រា២, មាត្រា២២, មាត្រា២៣, មាត្រា២៤, មាត្រា៣៧៥, មាត្រា៤០២, មាត្រា៤១៧, មាត្រា៤១៨ និងមាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីធានានូវសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ ក្នុងការទាមទារសំណងជំងឺចិត្តចំពោះព្យសនកម្មដែលខ្លួនបានទទួលរង ប៉ុន្តែ បណ្តឹងឧទ្ធរណ៍ ឬបណ្តឹងសាទុក្ខ ដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី មានអានុភាពតែទៅលើផលប្រយោជន៍ផ្នែករដ្ឋប្បវេណីប៉ុណ្ណោះ។ ក្នុងករណីដែលពុំមានបណ្តឹងឧទ្ធរណ៍របស់អយ្យការអមសាលាដំបូង ឬមហាអយ្យការអមសាលាឧទ្ធរណ៍, តុលាការ ដែលទទួលបណ្តឹងឧទ្ធរណ៍តែពីដើមបណ្តឹងរដ្ឋប្បវេណី អាចសម្រេចបានតែអំពីសំណងរដ្ឋប្បវេណីប៉ុណ្ណោះ ក្នុងករណីពិនិត្យឃើញមានកំហុសរបស់ជនជាប់ចោទ ប៉ុន្តែ តុលាការមិនអាចសម្រេចអំពីការដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌបានឡើយ។ ករណីនេះ ត្រូវអនុវត្តដូចគ្នាផងដែរចំពោះបណ្តឹងសាទុក្ខ។

ក្រៅពីប្រធានបទទាំង ៨ ខាងលើ, អង្គមហាសន្និបាត បានពិនិត្យ និងពិភាក្សាលើការងារពាក់ព័ន្ធនឹងការលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពនៃរដ្ឋបាលតុលាការ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងវិស័យយុត្តិធម៌ក្នុងបរិបទគណនេយ្យភាពសមិទ្ធកម្ម។ ចំពោះការងារនេះ, **ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** បានធ្វើការណែនាំ ដូចខាងក្រោម៖

**១**-អង្គភាពរដ្ឋបាលតុលាការ ត្រូវពង្រឹងប្រសិទ្ធភាពនៃការអនុវត្តតួនាទីរបស់ខ្លួនក្នុងនាមជាសេនាធិការផ្នែករដ្ឋបាល, ហិរញ្ញវត្ថុ និងបច្ចេកទេស ទាំងសម្រាប់សាលាជម្រះក្តី ទាំងសម្រាប់អង្គការអយ្យការអមសាលា

KR

ជម្រះក្តីគ្រប់ជាន់ថ្នាក់។ សាលាច្បាប់នៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា និងអង្គភាពរដ្ឋបាលតុលាការនៃសាលាជម្រះក្តីនានា ត្រូវសហការគ្នារៀបចំផែនការពង្រឹងសមត្ថភាពមន្ត្រីអង្គភាពរដ្ឋបាលតុលាការ ដោយត្រូវចាប់ផ្តើមបណ្តុះបណ្តាលចាប់ពីឆមាសទី២ ឆ្នាំ២០២៤ តទៅ។

២-ប្រគល់ភារកិច្ចដល់ក្រុមការងារតាមដាន វាយតម្លៃ និងដោះស្រាយបញ្ហាប្រឈមលើការងារថវិកាក្នុងវិស័យយុត្តិធម៌របស់ក្រសួងយុត្តិធម៌ ដើម្បីរៀបចំ និងអនុវត្តឱ្យមានប្រសិទ្ធភាពនូវវគ្គបណ្តុះបណ្តាលពាក់ព័ន្ធនឹងការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដល់មន្ត្រីរដ្ឋបាលតុលាការ សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃការរៀបចំ និងការអនុវត្តថវិកានៅតាមសាលាជម្រះក្តីនីមួយៗ។

បន្ថែមលើសេចក្តីសម្រេចចិត្តរបស់អង្គមហាសន្និបាត, **ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធានគណៈអធិបតី** ក៏បានផ្តល់ការណែនាំបន្ថែមចំពោះមហាសន្និបាត ដែលមានខ្លឹមសារដូចមានភ្ជាប់មកជាមួយ។

អាស្រ័យហេតុនេះ, សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំក្រសួងយុត្តិធម៌ និងអង្គភាពចំណុះក្រសួងយុត្តិធម៌, ជាចៅក្រម ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង មន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធទាំងអស់** ចូលរួមអនុវត្តសេចក្តីសម្រេចចិត្តរួមរបស់អង្គមហាសន្និបាតខាងលើឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួនសំដៅពង្រឹងប្រសិទ្ធភាពការងារ, ប្រសិទ្ធភាពនៃការផ្តល់សេវាយុត្តិធម៌ និងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ ដើម្បីជាឧត្តមប្រយោជន៍នៃវិស័យយុត្តិធម៌ និងឧត្តមប្រយោជន៍របស់ជាតិ និងប្រជាជនកម្ពុជា។

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែ ជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**ប្រធានតុលាការកំពូល**

**បណ្ឌិត ឌិត មុន្ទី**

**អគ្គព្រះរាជអាជ្ញា**
**នៃមហាអយ្យការអមតុលាការកំពូល**

**ជា លាង**